ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ជួបឯកឧត្តម ឯកអគ្គរដ្ឋទូតកាណាដា ប្រចាំកម្ពុជា



នៅរសៀលថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ២០១៤ ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានទទួលជួប ឯកឧត្តម **Phillip Calvert** ឯកអគ្គរដ្ឋទូតនៃប្រទេសកាណាដា ប្រចាំកម្ពុជា ដើម្បីពិភាក្សាការងារ នៅទីស្តីការក្រសួង ។

ឯកឧត្តម **Phillip Calvert** ឯកអគ្គរដ្ឋទូតនៃប្រទេសកាណាដាប្រចាំកម្ពុជា បានសម្តែងនូវទឹកចិត្តរីករាយ ចំពោះជំនួបពិភាក្សា និងផ្តល់សារៈសំខាន់ចំពោះតួនាទីដឹកនាំរបស់ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ក្នុងការជម្រុញអភិវឌ្ឍន៍លើវិស័យឧស្សាហកម្ម និងសិប្បកម្ម ជាពិសេសលើវិស័យសហគ្រាសខ្នាតតូច និងមធ្យម (SME) ដែលឯកឧត្តមមានការចាប់អារម្មណ៍និងចង់សិក្សាស្វែងយល់លើវិស័យនេះ នៅកម្ពុជា។





ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានសម្តែងការស្វាគមន៍ និងវាយតម្លៃខ្ពស់ចំពោះបេសកកម្មការទូត របស់ឯកឧត្តម **Phillip Calvert** នៅកម្ពុជា ។ ទាក់ទងនិងវិស័យសហគ្រាសខ្នាតតូចនិងមធ្យម (SME) ឯកឧត្តមសង្ឃឹមថា: កម្ពុជានឹងទទួលបាននូវការផ្លាស់ប្តូរបទពិសោធន៍ និងជំនួយបច្ចេកទេសពីប្រទេសកាណាដា ពីព្រោះវិស័យនេះ ទោះបីប្រទេសកាដាណា ជាប្រទេសអភិវឌ្ឍន៍ក៏ដោយ តែមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ គឺពឹងផ្អែកយ៉ាងខ្លាំងលើវិស័យ SME ។ ជាក់ស្តែងជាង៩៩% នៅក្នុងប្រទេសកាណាដា ត្រូវបានចាត់ថ្នាក់ជាវិស័យ SME ។ ក្នុងនោះ ៧៥% ជាប្រភេទ SME ធុនតូចបំផុត ដែលមាននិយោជិត តិចជាង១០នាក់ ហើយវិស័យ SME បានផ្តល់ការងារប្រមាណជាង៧លាននាក់ ។

ទាក់ទងនិងវិស័យ SME នៅកម្ពុជា ឯកឧត្តម ទេសរដ្ឋមន្ត្រី បានបញ្ជាក់ថា៖ នៅកម្ពុជា មានសហគ្រាសខ្នាតតូច និងមធ្យម ប្រមាណជាង ៥សែនមូលដ្ឋាន ហើយការចុះបញ្ជីទទួលស្គាល់បានត្រឹមតែជិត៤ម៉ឺនមូលដ្ឋានប៉ុណ្ណោះ ។ ប៉ុន្តែ ដោយការគិតគូរដ៏វៀងវៃរបស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ក្នុងឱកាសបើកវេទិការរវាងរាជរដ្ឋាភិបាល និងវិស័យឯកជនកន្លងទៅនេះ សម្តេចបានសម្រេចឱ្យការចុះបញ្ជី សហគ្រាសខ្នាតតូច និងមធ្យម គឺប្រមូលផ្តុំនៅតែក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប៉ុណ្ណោះ ។ កត្តានេះ កម្ពុជា កំពុងត្រូវការជំនួយបច្ចេកទេស ក្នុងការចុះបញ្ជីតាមប្រព័ន្ធ On Line ។ ប៉ុន្តែ ក្នុងដំណាក់កាលនេះ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម កំពុងកៀងគរឱ្យសហគ្រាសខ្នាតតូច និងមធ្យមទាំងអស់មកចុះបញ្ជីនៅទីស្តីការក្រសួងតាមប្រព័ន្ធធម្មតាសិន និងណែនាំឱ្យម្ចាស់សហគ្រិនបានស្វែងយល់ពីអត្ថប្រយោជន៍នៃការចុះបញ្ជី ពីព្រោះក្រសួងមានគោលនយោបាយគ្រប់គ្រង និងគាំទ្រលើវិស័យនេះ ក្នុងទិសដៅជួយជម្រុញការប្រកួតប្រជែងក្នុងសហគមន៍អាស៊ាន ក៏ដូចជាលទ្ធភាពបើកច្រកទីផ្សារទៅកាន់ប្រទេសផ្សេងៗទៀត ។ ជាមួយគ្នានេះ ឯកឧត្តម ទេសរដ្ឋមន្ត្រី ក៏បានជម្រាបជូនផងដែរថា៖ ក្រុមប្រឹក្សាស្តង់ដាជាតិកម្ពុជា ទើបសម្រេចយកស្តង់ដាកូដិចអន្តរជាតិ ធ្វើជាស្តង់ជាតិ សម្រាប់ផលិតផលម្ហូបអាហារនៅកម្ពុជា ដែលកិច្ចការនេះ យើងក៏ត្រូវការផ្សព្វផ្សាយឱ្យម្ចាស់សហគ្រិន សិក្សាស្វែងយល់ និងផ្លាស់ប្តូរខ្សែសង្វាក់ផលិតកម្ម នូវអ្វីដែលពួកគេនៅមានកង្វះខាតផ្នែកស្តង់ដាផលិតកម្ម ។

ឯកឧត្តម ឯកអគ្គរដ្ឋទូតកាណាដាប្រចាំកម្ពុជា បានវាយតម្លៃខ្ពស់ ចំពោះការដឹកនាំរបស់ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ហើយសង្ឃឹមថា៖ វិស័យ SME នៅកម្ពុជា នឹងទទួលបានការរីកចម្រើនទៅមុខ ហើយភាគីកាណាដា នឹងត្រៀមសហការ និងផ្លាស់ប្តូរបទពិសោធន៍ ជាមួយកម្ពុជា ពីព្រោះកម្ពុជាមានចំណែកទីផ្សារនាំចេញទៅប្រទេសកាណាដាយ៉ាងធំផងដែរ តាមរយៈភាពអនុគ្រោះពាណិជ្ជកម្មដែលប្រទេសកាណាដា បានផ្តល់មកកម្ពុជា ។

